# ដំណាំខាត់ណាផ្ការដូវវស្សា
# Cauliflower off Season

## I. **ការជ្រើសរើសពូជ** :

ជាទូទៅខាត់ណាផ្កា ជាប្រភេទដំណាំត្រូវការអាកាសធាតុត្រជាក់។ កាលណាគេដាំវានៅតំបន់ដែល មានសីតុណ្ហភាពទាបចន្លោះពី ១៨-២៥អង្សាសេ នោះផ្ការីកធំ ហើយគ្មានទទួលរងការបំផ្លាញពីសត្វល្អិតចង្រៃឡើយ។ ដោយសារតំរូវការពូជសំរាប់ដាំដុះក្នុងតំបន់ក្តៅ គេបង្កាត់ពូជ ឱ្យវាមានភាពធន់ទ្រាំនិង អាកាសធាតុក្តៅ ប៉ុន្តែផ្កាតូចជាងពូជសំរាប់ដាំតំបន់ត្រជាក់។ លទ្ធផលពិសោធន៍បានបង្ហាញឱ្យឃើញថា : ពូជមក ពី ជប៉ុន តៃវ៉ាន់ និងប្រទេសថៃ ទទួលផលច្រើន ជាងពូជមកពីហុងកុង ហូឡង់ បារាំង និងអាមេរិច។




**សញ្ញារូបដំរីលេខ ៦០ សំរាប់ដាំរដូវវស្សា**

នៅរដូវវស្សាឆ្នាំ ២០០៦-២០០៧ កន្លងទៅលទ្ធផល ពិសោធន៍ពូជថ្មីឈ្មោះ **នាងរូបដំរីលេខ៦០** ដែល ផលិតដោយប្រទេស ថៃផ្ការីកធំល្អ នៅរដូវវស្សា ធន់ទ្រាំនិងជំងឺរលួយផ្កា ពូជនេះមានសញ្ញាសំគាល់រូបដំរីជាប់និងគំរបកំប៉ុង វាមានអាយុកាលលូតលាស់ ៦០ថ្ងៃ ក្រោយដាំនោះផ្ការបស់វាល្អមកាត់។

## II. **វិធីសាស្ត្របណ្តុះកូនខាត់ណាផ្ការដូវវស្សា**

ខាត់ណាផ្កាជាដំណាំអំបូរស្ពៃ។ ក្រោយពីដុះពន្លកភ្លាម ក្លិនរបស់វាបានទាក់ទាញឱ្យប្រភេទសត្វល្អិតម្យ៉ាងតូចៗខ្មៅៗ ចោះស៊ីបំផ្លាញភ្លាមធ្វើឱ្យការផលិតកូនមានការពិបាក ម្យ៉ាងទៀតជំងឺរលាកគល់ក៏កើតមានច្រើនជាងរដូវត្រជាក់ ។ ដើម្បីបណ្តុះកូនខាត់ណាផ្កាឱ្យបានល្អ យើងត្រូវអនុវត្តនូវវិធីសាស្ត្រសំខាន់ៗដូចតទៅ :

### **១-ការរៀបចំថ្នាលបណ្តុះ** :

តំបូងត្រូវជ្រើសរើសយកដីទួល ស្រឡះឆ្ងាយពីម្លប់ឈើ រួចកាប់បំផុសដី ហើយពូនរងឱ្យខ្ពស់កំពស់ ២៥-៣០សង់ទីម៉ែត្រ តាមទិសបណ្តោយថ្ងៃ បន្ទាប់មកបង្ហាប់រងឱ្យស្មើល្អ សំរាប់ដាក់កញ្ច្រែងបណ្តុះ, កន្ទោងបណ្តុះ ឬ ស្បោងបណ្តុះដោយធ្វើដំបូលសំណាញ់បៃតងការពារកំដៅ និងពន្លឺថ្ងៃ ព្រមទាំងគ្រាប់ភ្លៀង ឱ្យខ្ពស់ផុតក្បាល ចំពីលើរងសំរាប់បណ្តុះ ។



**ដំបូលបៃតងការពារពន្លឺ និង កំដៅថ្ងៃ**

### **២-របៀបលាយដីបណ្តុះកូន** :

នៅរដូវធម្មតា គេបណ្តុះកូននិងថ្នាលផ្ទាល់ដី។ ប៉ុន្តែនៅរដូវវស្សា គេពុំអនុវត្តរបៀបនោះឡើយ គឺ បណ្តុះក្នុងកន្ទោង កញ្ច្រែង ឬស្បោង ទើបងាយស្រួលក្នុងការថែទាំ ។ ដូចនេះដីលាយសំរាប់បណ្តុះកូនដើម្បីឱ្យកូនខាត់ណាផ្កាដុះលូតលាស់លឿនពុំមានមេរោគបំផ្លាញ គឺត្រូវអនុវត្តន៍ដូចខាងក្រោម:

- យកដីមានជីជាតិស្រទាប់លើ ឬដីដំបូកៈ មកហាលឱ្យស្ងួត រួចវាយឱ្យម៉ត់រែងយកកន្ទក់ ចំនួនមួយធុង,

-យកផេះអង្កាម មកត្រាំទឹកមួយយប់ ដើម្បី ឱ្យសាបជាតិប្រៃ ចំនួនមួយធុង,

- យកកម្ទេចស្រកីដូងម៉ត់ ចំនួនមួយធុង,

- យកជីកំប៉ុស្តិ៍ ឬជីលាមកគោពុកយូរឆ្នាំ ហាលឱ្យស្ងួត រួចវាយឱ្យម៉ត់រែងយកកន្ទក់ ចំនួនមួយធុង ។ យកវត្ថុធាតុទាំង ៤ មុខមកលាយចូល គ្នា ហើយដុតសំលាប់មេរោគឱ្យឆ្អិន (ធុងត្រូវ វាស់ប៉ុនគ្នា) ។



ដុតដី សំលាប់មេរោគអោយឆ្អិន

## ៣. របៀបបណ្តុះកូនខាត់ណាផ្កា :

តំបូង យកកញ្ច្រែងបណ្តុះទៅតំរៀបលើ ថ្នាលក្រោមដំបូលបៃតង រួចយកដីដុតឆ្អិនហើយ ទៅដាក់បំពេញឱ្យជិតពេញ ។ បន្ទាប់មក យកគ្រាប់ ខាត់ណាផ្កា ទៅដាក់តាមរន្ធនៃកញ្ច្រែងពីរៗគ្រាប់ ហើយលប់ដីឱ្យជិតពីលើ រួចគ្រប់ចំបើងស្ងួតឱ្យក្រាស់ បន្ទាប់មក ស្រោចទឹកឱ្យជោគ។ ក្រោយមកយក ថ្នាំការពារជំងឺផ្សិតយកលាយ ទឹកស្រោចតាមក្រោយ ។

ក្រោយពីការដាក់បណ្តុះត្រូវដោតបង្កង ឬស្សី ធ្វើតំបូលប្រក់សំណាញ់ញឹកការពារសត្វល្អិត ជើងសំណាញ់សង្កត់ដីឱ្យជាប់ ។



គ្របការពារសត្វល្អិតចង្រៃ

## ៤.របៀបថែទាំកូនខាត់ណា :

ក្រោយពីការដាក់បណ្តុះរយៈពេលពីរថ្ងៃ ត្រូវបកចំបើងនោះចេញ ហើយប្រក់សំណាញ់ឱ្យជិត ទៅវិញភ្លាម ។ រយៈពេល ៥-៦ ថ្ងៃក្រោយមកត្រូវ ស្រោចថ្នាំផ្សិតការពារជាបន្ត រហូតដល់កូនខាត់ណា មានអាយុ ១០-១២ ថ្ងៃ ទើបដករំលោះកូនចេញ រក្សាទុកតែមួយដើមក្នុងមួយរន្ធ ហើយស្រោចជី បំប៉នបន្តិចៗ មួយស្លាបព្រាបាយជីអ៊ុយរ៉េលាយទឹក មួយធុងចំណុះ ១៨លីត្រ ស្រោចឱ្យជោគពេញលើ រងកូនខាត់ណា ។ ការស្រោចជីលើកទី២ ធ្វើឡើង ក្រោយពីកូនខាត់ណា មានអាយុ ១៨-២០ ថ្ងៃ ។ ការស្រោចទឹក ស្រោចជីមិនត្រូវបើក រឺ បកសំណាញ់ ចេញឡើយ ការដកស្មៅ គឺ បង្ហើបសំណាញ់ បន្តិចៗ លូតដៃចូលហើយដក ។

## III. ការរៀបចំថ្នាល និងគ្រួបរងដាំ :

ខាត់ណាផ្កាដុះលូតលាស់ល្អលើដីមានជីជាតិ ល្អ ដីឥដ្ឋ ឬខ្សាច់ខ្លាំងធ្វើឱ្យខាត់ណាផ្កាលូតលាស់យឺត ផ្កាតូច ដូចនេះគេត្រូវជ្រើសរើសដីអោយល្អ ។ ត្រូវ

ភ្ជួរដី នោះហាលឱ្យបានច្រើនដង និងច្រើនថ្ងៃ ប្រមូលយក ស្មៅចេញ ។

**១. ការលើករងដាំ :**

ក្រោយពីរាស់ដីរួចហើយត្រូវលើករង សំរាប់ដាំតាមបណ្តោយទិសទឹកហូរ ទទឹងរង ១ម៉ែត្រ កំពស់រង ៣០សង់ទីម៉ែត្រ ប្រវែងរង ១០-១៥ម៉ែត្រ ។ ក្រោយពីលើករងហើយ គេត្រូវគ្របកៅស៊ូពណិស នៅពេលមេឃភ្លៀង មិនត្រូវទុកដីឱ្យត្រូវភ្លៀងសើម ការដាំដុះមិនល្អឡើយ ។

**២. ការដាក់ជីនិងគ្របរងសំរាប់ដាំ:**



ការគ្រប់រង មុនពេលដាំ

ក្រោយពីការលើករងរួចហើយ យកជីកំប៉ុស្តិ៍ ឬជីលាមកគោ ជ្រូក ។ល។ ចំនួន ៣បង្គី ជី ១៥-១៥-១៥ ទំងន់ ២០០ក្រាម ជីទាំងនោះទៅបាចលើរង ហើយជ្រុលបប់និងកៀររងឱ្យស្មើថែមទាំង បង្ហាប់តែមរងឱ្យហាប់ត្រង់ស្មើទើបយក កៅស៊ូគ្របដីគ្របលើរង ហើយសង្កត់ដីពីលើដោយដោតខ្ទាស់ កៅស៊ូតែម៧រងឱ្យ ជាប់ងាយស្រួលក្នុងការចោះរន្ធ ដាំ ។

## IV. ការដាំ និងថែទាំខាត់ណាផ្កា :

ខាត់ណារដូវវស្សា គេត្រូវដាំឱ្យញឹកជាងរដូវប្រាំង ដើម្បីឱ្យស្លឹករបស់វាគងលើគ្នា ដើម្បីការពារផ្កា ដូចនេះមុនដាំគេត្រូវអនុវត្តនូវលក្ខណះពិសេសមួយចំនួន :

**១. របៀបដាំខាត់ណា :**

មុននឹងដាំ ត្រូវចោះរន្ធកៅស៊ូដែលគ្របលើរងជាមុនដោយកំប៉ុងក្តៅ របៀបចោះឱ្យស្មើល្អ ដាក់ខ្សែបន្ទាត់ទទឹងរង ហើយចោះតាមខ្សែបន្ទាត់ ។



ការចោះរន្ធដាំ

ការចោះធ្វើជាពីរជួរ ចន្លោះជួរ ៦០សង់ទីម៉ែត្រ ចន្លោះគុម្ព៣០សង់ទីម៉ែត្រ ។

ចំពោះកូនខាត់ណាផ្កាវិញ ត្រូវស្រោចទឹកឱ្យជោគ ១៥.២០នាទី មុនហើយដកជំរើសយកកូនណាដែល ធំហើយថ្លោសស្មើគ្នាដាក់កញ្ច្រែងដោយឡែក ។ ការដាំគឺ កូនធំដាំដោយរងកូនធំ មុនដាំបុករណ្តៅជំរៅ ៥-៧ សង់ទីម៉ែត្រ តាមរន្ធកៅស៊ូ រួចដាក់កូនដាំមួយរណ្តៅមួយដើម។ ដាំហើយស្រោចទឹកភ្លាម ។



កូនដំណាំខាត់ណាផ្កាអាយុ ២៩ថ្ងៃ

**២. ការស្រោចទឹក :**

បន្ទាប់ពីដាំបានបីថ្ងៃ ត្រូវស្រោចទឹក ៣ដងក្នុងមួយថ្ងៃ គឺព្រឹក ថ្ងៃត្រង់ និងល្ងាច ក្នុងករណីគ្មានភ្លៀងធ្លាក់។

ក្រោយមកគេត្រូវបូមទឹកបញ្ចូលតាមចន្លោះរងទប់ទឹក ទុករយៈពេល ៤ ម៉ោង ទើបកាយបង្ហូរចេញ។ ចាប់ពីដាំហើយរហូតដល់ខាត់ណាមានសន្លឹក ៥-៦ វាត្រូវការទឹកមធ្យម វគ្គផ្ការីកធំល្មមប្រមូលផល វា ត្រូវការទឹកច្រើន ។

### ៣-ការដាក់ជីបំប៉ន :

ខាត់ណាផ្កាត្រូវការសារធាតុសរីរាង្គច្រើនក្នុងទំរង់រលាយ ដូចជាជីលាមកមាន់ត្រាំជាមួយទឹកនោមជាដើម ។ គេត្រូវយកទឹកជីនោះមកលាយទឹកស្រោចរយៈពេល ៥-៧ ថ្ងៃម្តង ក៏រិតលាយ ២លីត្រ លាយទឹក ១៨លីត្រ ។ ដោយឡែកការដាក់បន្ថែម ជីចែកចេញជា ៤ដំណាក់កាលធំៗគឺ:

**-ការដាក់ជីបំប៉នលើកទី១:**

ប្រភេទជីអ៊ុយរ៉េសុទ្ធ ទំងន់ ១០០ក្រាម ដាក់ក្រោមកៅស៊ូតាមចន្លោះគុម្ព ក្រោយដាំរយៈពេល១០ថ្ងៃ ។

**- ការដាក់ជីបំប៉នលើកទី២ :**

ប្រភេទជី ១៥-១៥-១៥ ទំងន់ ១០០ក្រាម លាយជី ០.០.៤៦ ទំងន់៥០ក្រាម ដាក់ចំនួនមួយរង។ បង្ហើបរន្ធកៅស៊ូ បោះចូលតាមចន្លោះជួរ ហើយបញ្ចូលទឹកតាម ចន្លោះរង ដើម្បីឱ្យជីរលាយក្រោយដាំបានរយៈពេល២០ ថ្ងៃ ។

**-ការដាក់ជីបំប៉នលើកទី៣:**

ប្រភេទជីអ៊ុយរ៉េ សុទ្ធទំងន់ ៥០ក្រាម បោះចូលក្រោមកៅស៊ូតាមចន្លោះជួរ ក្រោយដាំរយៈពេល ៣០ថ្ងៃ ។

**- ការដាក់ជីបំប៉នលើកទី៤ :**

ប្រភេទជី ១៥-១៥-១៥ ទំងន់ ៥០ក្រាម លាយជីអ៊ុយរ៉េ ៥០ក្រាមដាក់តាមចន្លោះគុម្ពហើយបញ្ចូលទឹកឱ្យសើមជី ក្រោយ ដាំរយៈពេល ៤០-៤៥ថ្ងៃ។

## V. ជំងឺសត្វល្អិត និងការគ្រប់គ្រង :

នៅរដូវវស្សា ការបំផ្លាញដោយសត្វល្អិតមានក៏រិតទាបប៉ុន្តែជំងឺបំផ្លាញច្រើនជាង ដូចនេះយើងត្រូវមានវិធានការគ្រប់គ្រងដូចតទៅ :

### ១-សត្វល្អិតចង្រៃសំខាន់ៗ :

នៅរដូវវស្សា យើងជួបជាញឹកញាប់គឺ ដង្កូវបី ប្រភេទដែលបំផ្លាញខុសៗគ្នាគឺ:

- **ដង្កូវកាត់ដើម :** ដង្កូវនេះរស់នៅក្នុងដីពេលយកដំណាំទៅដាំលើដី វានឹងចេញមកកាត់គល់កូនខាត់ណាស៊ីជាអាហារនៅពេលយប់ ។ វិធានការការពារនឹងកំចាត់គឺ ក្រោយពីដាំ ហើយភ្លាមគេរោយថ្នាំ ពុលមួយប្រភេទឈ្មោះ ហ្វុយរ៉ាដង់ក្បែរៗគល់កូនខាត់ណា ។

- **ដង្កូវស៊ីរូងកំពូលស្លែ :** នៅក្នុងវគ្គលូតលាស់ក្រោយដាំរយៈពេលមួយអាទិត្យ តែងតែពិនិត្យឃើញមានដង្កូវនេះ ស៊ីរូងបណ្តូលខាត់ណាធ្វើឱ្យខ្ទាក់ត្រួយ រឺ ពន្លក លែងលូតលាស់។ ដើម្បីកំចាត់ដង្កូវនេះ គេប្រើថ្នាំមួយប្រភេទឈ្មោះប៊ីយូស៊ីន លាយជាមួយ មេទីលផូសស្វេត ក៏រិតប្រើប៊ីយូស៊ីន ២កញ្ចប់ (១កញ្ចប់ ១០សេសេ) មេទីលផូសស្វេត ៣០សេសេ លាយ ទឹក ១៨លីត្រ បាញ់មុនពេលថ្ងៃរះ ។




**ថ្នាំកំចាត់ដង្កូវស៊ីរូងកំពូល**

- **ដង្កូវហ្វូងស៊ីស្លឹកនិងផ្កា:** ដង្កូវប្រភេទនេះញាស់ជាសំបុកៗ បង្កជាហ្វូងនៅក្រោមស្លឹក ពេលខាត់ណាវិវឌ្ឍន៍ក្នុងវគ្គបង្កបង្កើតផ្កា វាស៊ីស្លឹក និងស៊ីផ្កាខាត់ណាពេលខាត់ណាមានផ្កា។ ការ កំចាត់ គឺ ពិនិត្យមើលពង និងកូនញាស់ថ្មីៗ ត្រូវកាត់ទាំងស្លឹកដែលកូនញាស់រស់នៅដាក់ក្នុងទឹកមាន លាយប្រេងកាត រឺ ប្រេងម៉ាស៊ូត ហើយយកទៅ ដុតចោល និងបាញ់ថ្នាំ ការពារពងមិនឱ្យញាស់ដូចដង្កូវស៊ីរូងបណ្តូលស្ពៃដែរ។

## ២. ជំងឺសំខាន់ៗនៅរដូវវស្សា :

នៅរដូវវស្សា ខាត់ណាជួបការបំផ្លាញដោយជំងឺពីរប្រភេទគឺ ជំងឺជាំផ្កា និងជំងឺ គួតគល់ ។ ដើម្បីការពារជំងឺនេះ គេមានវិធានការការពារដូចតទៅ :

- **ជំងឺគួតគល់ រលួយឫស :** ជំងឺនេះ ធ្វើឱ្យស្បែកគល់កូនខាត់ណារលាក ហើយស្ងួតក្បែរៗដី វាចាប់ផ្តើមកើតលើកូនខាត់ណាតាំងពីនៅ វគ្គកូនសំណាបមុនដកយកទៅដាំ ជំងឺនេះឈ្មោះ ដាំភីងអហ្វ (Damping-off) មុនពេលដកយកទៅដាំ គេយក ថ្នាំផ្សិតមកលាយទឹកបាញ់ឱ្យជោគ ហើយពេលដក កូនត្រូវពិនិត្យមើលគល់វាជាមុន ។

- **ជំងឺជាំផ្កា :** នៅក្នុងវគ្គចេញផ្កាតំបូង មេរោគចាប់ផ្តើមកើត និងវិវឌ្ឍន៍បណ្តើរៗ ពេលផ្ការីកធំលេចចេញសញ្ញាជាំៗ ហើយរលួយព្រមទាំងឆ្លងយ៉ាងលឿន។ វាបង្កដោយមេរោគពីរក្រុមគឺ ក្រុមផ្សិត និងបាត់តេរី។ ដើម្បីការពារជំងឺនេះ ក្រោយពីដាំ បានរយៈពេល ២សប្តាហ៍ឡើងទៅ ត្រូវព្យាយាមយកថ្នាំផ្សិតមកលាយទឹកបាញ់ ៥-៧ថ្ងៃម្តង ។



**ជំងឺជាំផ្កា**

## VI. ការប្រមូលផលខាត់ណា :

នៅពេលផ្ការីកមានទំហំ ៣-៤សង់ទីម៉ែត្រ គេត្រូវ ចាប់ស្លឹកអមផ្កាពត់រកគ្នាខ្ទាស់ឱ្យជាប់បាំងពន្លឺ និង កំដៅថ្ងៃ រហូតដល់ផ្ការីកធំល្មមកាត់គេត្រូវកាត់ផ្កា ខាត់ណាប្រើដោយកាំបិតមុត កាត់ដើមខាត់ណា ដោយរក្សាទុកស្លឹកអមផ្កាចំនួន ៥-៦ សន្លឹក (កាត់ ពេលម៉ោង ៨-១០ ព្រឹក) ក្រោយពីកាត់ហើយ បញ្ជូនផ្កាយកទៅដាក់ក្រោមម្លប់ត្រជាក់ភ្លាម បន្ទាប់ មកកាត់ស្លឹកអមផ្កាប៉ែកខាងក្រោមចេញចំនួន ២-៣ សន្លឹកឱ្យត្រឹមផ្កា ហើយស្លឹកដែលនៅសល់ ត្រូវបត់គ្របផ្កាតំរៀបទៅក្នុងឧបករណ៍ដឹកជញ្ជូនពូជ រដូវវស្សាអាយុកាល ប្រមូលផល ក្រោយដាំចំនួនពី ៥០-៦០ ថ្ងៃ ទិន្នផលជាមធ្យម ១៨-២២តោន ក្នុង មួយហិចតា។



**តំរៀបផ្កាក្រោយកាត់**



**ផ្កាល្មមកាត់**


រៀបរៀងដោយ

ម៉ុង វ៉ាន់ឌី អ្នកស្រាវជ្រាវដំណាំបន្លែនៅកម្ពុជា

កែសំរួលដោយ

កាំង ចាន់ឡែន អ្នកសំរបសំរួលខ្សែរចង្វាក់ផលិតកម្ម

ដំណាំបន្លែ គំរោង CADF